រូបថត៖ អេនគ្រាស នីលសុន (Andreas Nilsson)

## *អ៊ីវ៉ូនី (Yvonne) កើតឆ្នាំ១៩៤៤*

ខ្ញុំមិនដែលធ្លាប់មានចិត្តស្រឡាញ់លើមនុស្សប្រុសណាម្នាក់ឡើយ គឺមិនដែលមានទាល់តែសោះ។ វាគ្រាន់តែជាការសម្តែងប៉ុណ្ណោះ ដោយសារតែអ្នកចាំបាច់ត្រូវតែធ្វើបែបនេះ។ ដោយសារខ្ញុំពិតជាមិនបានដឹងអ្វីទាល់តែសោះអំពីរឿងទាំងអស់នេះ...។

ខ្ញុំមានស្នេហា នៅពេលដែលខ្ញុំបានចាប់ផ្តើមចូលធ្វើការ គឺនៅពេលខ្ញុំមានអាយុ ១៦ ឬ ១៧ ឆ្នាំ។ នាងមានអាយុច្រើនជាងខ្ញុំ គឺច្រើនជាងខ្ញុំឆ្ងាយណាស់ ហើយខ្ញុំបានចាប់ចិត្តស្រឡាញ់លើរូបនាងយ៉ាងខ្លាំង។ម្តងម្កាល នាងបានទៅជួបបុរសម្នាក់នោះ ហើយខ្ញុំក៏បានប្រចណ្ឌបុរសនោះយ៉ាងខ្លាំង នៅពេលនោះខ្ញុំពិតជាមិនដឹងថាតើវាជាអ្វីនោះទេ។ ប៉ុន្តែអ្វីដែលចម្លែកនោះគឺថា ជំនួយការម្នាក់នៅកន្លែងធ្វើការ នាងបានយល់។ ខ្ញុំមិនបានដឹងអ្វីទាល់តែសោះអំពីការស្រឡាញ់មនុស្សភេទដូចគ្នា។ តើវាគឺជាអ្វីទៅ? ប៉ុន្តែនៅពេលនោះ នាងបានប្រាប់ខ្ញុំ។ ក្រោយមក មានអត្ថបទនានាបានចុះផ្សាយលើទំព័រសារព័ត៌មានញូវយ៉កថា អ្នកអាចទទួលបានការចាក់ថ្នាំប្រឆាំងនឹងការស្រឡាញ់មនុស្សភេទដូចគ្នាបាន។ នាងបានបង្ហាញអត្ថបទសារព័ត៌មាននោះមកកាន់ខ្ញុំ។ ដូច្នោះខ្ញុំក៏បានកំពុងគិត៖ តើខ្ញុំកំពុងតែមានជំងឺឬ បើមិនដូច្នោះទេ តើនេះគឺជាអ្វីទៅ?

ខ្ញុំបានបន្តចាប់ចិត្តស្រឡាញ់មនុស្សស្រី - ប៉ុន្តែមិនមានការឈានដល់ទំនាក់ទំនងផ្លូវភេទនោះទេ...។ ដូច្នេះហើយ ខ្ញុំហាក់ដូចជាបានចំណាយយុវវ័យរបស់ខ្ញុំឥតប្រយោជន៍។ នៅពេលដែលខ្ញុំមានអាយុប្រហែល ១៨-១៩ ឆ្នាំ ខ្ញុំក៏បានចាប់ផ្តើមបោះបង់គំនិតនេះចោលដោយគិតថា៖ តើខ្ញុំមានបញ្ហាអ្វីទៅ? តើវាមានតែខ្ញុំម្នាក់ឯងទេឬ? តើខ្ញុំនឹងត្រូវធ្វើអ្វីបន្តទៀត? ខ្ញុំមានការពិបាកចិត្តយ៉ាងខ្លាំង និងចេះតែចាក់ចម្រៀងបុណ្យសពស្តាប់ ដោយមិនចង់រស់នៅតទៅទៀតឡើយ។ ប៉ុន្តែក្រោយមក នៅពេលខ្ញុំមានអាយុប្រហែល ២០ ឆ្នាំ ខ្ញុំបានអានអំពីរឿងរបស់ក្មេងស្រីម្នាក់នេះ ឈ្មោះ អាហ្វតុនប្លាដេត (Aftonbladet) នៅក្នុងសារព័ត៌មានពេលល្ងាច ដោយនាងកំពុងតែសួរ និងរៀបរាប់នូវអ្វីៗទាំងអស់ ដែលខ្ញុំបានគិត និងកំពុងឆ្ងល់ ថាតើគួរងាករកជំនួយឯណា។ នាងបានទទួលនូវចម្លើយមួយដ៏ល្អអស្ចារ្យ គឺថា នាងត្រូវទាក់ទងជាមួយ RFSL (សហព័ន្ធនៃប្រទេសស៊ុយអែតដើម្បីសិទ្ធិរបស់នារីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់មនុស្សទាំងពីរភេទ និងមនុស្សកែភេទ)។ ខ្ញុំបានកាត់វាចេញពីសារព័ត៌មាននោះ ដោយគិតថានេះពិតជាអ្វីដែលខ្ញុំត្រូវធ្វើដែរ។ ដូច្នោះហើយខ្ញុំបានសរសេរលិខិតមួយច្បាប់ ដាក់វាក្នុងស្រោមសំបុត្រមួយ ហើយបានដាក់វាចោលនៅក្នុងថតតុអស់រយៈពេលមួយសប្តាហ៍។ ខ្ញុំមិនហ៊ានផ្ញើវាសោះ។ ទីបំផុតខ្ញុំក៏ចាប់ផ្តើមមានភាពក្លាហាន ហើយក៏បានដាក់វាចូលទៅក្នុងប្រអប់សំបុត្រ។ ដោយបានធ្វើបែបនោះ ខ្ញុំអាចនឹងហែកប្រអប់សំបុត្រនោះឲ្យបើកចំហ ដោយគិតថា ទេ ទេ ទេ។ ខ្ញុំគ្រាន់តែបានបើកចិត្តខ្លួនឯងឲ្យទូលាយប៉ុណ្ណោះ។

ប៉ុន្តែបន្ទាប់មក ពួកគេបានទូរសព្ទមកខ្ញុំ ហើយពួកយើងក៏បានណាត់ជួបគ្នា រួចខ្ញុំក៏បានទៅកាន់ទីនោះ និងបានជួបស្ត្រីចាស់ជាងខ្ញុំពីរនាក់។ ខ្ញុំមានអារម្មណ៍ថា អ្វីៗហាក់ដូចជាត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ។ ពេលចាកចេញពីកន្លែងនោះ ខ្ញុំសប្បាយចិត្តណាស់។

ប៉ុន្តែអ្វីដែលពិបាកបំផុតនោះគឺនៅកន្លែងធ្វើការ។ នៅពេលដែលអ្នកចូលធ្វើការវិញនៅថ្ងៃចន្ទ ហើយអ្នករាល់គ្នានិយាយថា៖ តើអ្នកចំណាយពេលចុងសប្តាហ៍របស់អ្នកយ៉ាងម៉េចដែរ? គឺថា ខ្ញុំ និងមិត្តប្រុសរបស់ខ្ញុំ...។ ខ្ញុំកំពុងតែស្ថិតក្នុងរយៈពេលនិយាយកុហកដែលខ្ញុំមិនចង់រំឭកនោះទេ។ ហើយអ្នកមិនដែលចាំថា អ្នកបាននិយាយអ្វីឆ្កួតបែបនោះឡើយ។

រហូតដល់ខ្ញុំអាយុ ៤០ ឆ្នាំ ទើបខ្ញុំមានភាពបើកចំហទាំងស្រុងអំពីរឿងនេះ ពោលគឺ បើកចំហទាំងស្រុង! ខ្ញុំបានឈានដល់ចំណុចដែលខ្ញុំមិនមានអ្វីត្រូវប្រកែកទៀតឡើយ។ នៅពេលនេះ ខ្ញុំប្រាប់មនុស្សគ្រប់គ្នាថា ខ្ញុំសប្បាយចិត្តណាស់។ ខ្ញុំមិនដែលចង់ធ្វើជាមនុស្សស្រឡាញ់ភេទដូចគ្នានោះឡើយ។ ខ្ញុំមានជីវិតល្អណាស់ ហើយរឿងរ៉ាវផ្សេងទៀតទាំងអស់នេះត្រូវបានបំភ្លេចចោល។